**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ២៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូល ដែលបានពីកម្រៃនៃការផ្តល់សេវារដ្ឋបាល និងសេវាសាធារណៈផ្សេងៗទៀតតាមរយៈការប្រគល់ ឬការធ្វើប្រតិភូកម្មមុខងារពីក្រសួង ស្ថាប័ននានានៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីការគ្រោង ការប្រមូល ការបែងចែក ការបង់ និងការប្រើប្រាស់ចំណូលដែលបានពីកម្រៃនៃការផ្តល់សេវារដ្ឋបាល និងសេវាសាធារណៈផ្សេងៗទៀតតាមរយៈការប្រគល់ ឬការធ្វើប្រតិភូកម្មមុខងារពីក្រសួង ស្ថាប័ននានានៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះចំណូលដែលបានពីកម្រៃនៃការផ្តល់សេវារដ្ឋបាល និងសេវាសាធារណៈផ្សេងៗទៀតតាមរយៈការប្រគល់ ឬការធ្វើប្រតិភូកម្មមុខងារពីក្រសួង ស្ថាប័ននានានៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត។

## ជំពូកទី២

## ការគ្រប់គ្រង ការបែងចែក និងការបង់ចំណូល

**មាត្រា៤.-**

រដ្ឋបាលរាជធានី ខេត្តត្រូវធ្វើការប៉ាន់ស្មានអំពីទំហំចំណូលប្រចាំឆ្នាំដែលអាចប្រមូលបានពីកម្រៃនៃការផ្តល់សេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត ដោយផ្អែកលើមូលដ្ឋានទិន្នន័យសមស្រប និងផ្អែកតាមប្រភេទ និងតម្លៃសេវាដែលបានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងត្រូវគ្រោងចំណូលដែលបានប៉ាន់ស្មាននេះនៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួនទៅតាមចំណាត់ថ្នាក់នៃមាតិកាថវិកា។

**មាត្រា៥.-**

រដ្ឋបាលរាជធានី ខេត្តត្រូវអនុវត្តការប្រមូលចំណូលពីកម្រៃសេវា និងកត់ត្រាជាចំណូលរបស់រដ្ឋបាលរាជធានី ខេត្តសាមី លើប្រភេទសេវាដែលក្រសួង ស្ថាប័នបានប្រគល់ ឬធ្វើប្រតិភូកម្មមុខងារជូនរដ្ឋបាលរាជធានី ខេត្ត តាមតម្លៃសេវាដែលបានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការទទួលចំណូលពីកម្រៃសេវាដោយផ្ទាល់ជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់របស់រដ្ឋបាលរាជធានី ខេត្ត ដែលបោះពុម្ព និងបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

រដ្ឋបាលរាជធានី ខេត្តត្រូវរៀបចំសលាកបត្របង់ចំណូល ឬដីកាសម្រង់សលាកប័ត្របង់ចំណូលថវិកា ចំពោះចំណូលសេវាដែលប្រមូលបាននៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត។

ចំណូលដែលទទួលបានតាមរយៈការផ្ទេរប្រាក់តាមប្រព័ន្ធធនាគារ ឬតាមរយៈភ្នាក់ងារផ្តល់សេវាផ្ទេរប្រាក់ត្រូវអនុវត្តតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ។

**មាត្រា៦.-**

ចំណូលដែលបានពីកម្រៃនៃការផ្តល់សេវានៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តត្រូវបែងចែកជាពីរចំណែក គឺ**ចំណែកទីមួយ**ជាចំណូលគុណប្រយោជន៍ថវិការបស់រដ្ឋបាលរាជធានី ខេត្ត និង**ចំណែកទីពីរ**ជាប្រាក់រង្វាន់សម្រាប់លើកកម្ពស់សមត្ថភាពស្ថាប័នដើម្បីពង្រឹងយន្តការប្រមូលចំណូល និងឧបត្ថម្ភលើកទឹកចិត្តបុគ្គលិកនៃរដ្ឋបាលរាជធានី ខេត្ត មន្ទីរ អង្គភាព ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធដទៃទៀត។

**មាត្រា៧.-**

ការបែងចែកចំណូលដែលបានពីកម្រៃនៃការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តតាមការបែងចែកដូចមានកំណត់ក្នុងប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ចំពោះប្រភេទសេវាដែលរដ្ឋបាលរាជធានី ខេត្តបានទទួលតាមរយៈការផ្ទេរមុខងារក្នុងការផ្តល់សេវា និងទទួលបានចំណែកប្រាក់រង្វាន់ពីការបែងចែកចំណូលពីក្រសួង ស្ថាប័នពាក់ព័ន្ធរួចហើយ រដ្ឋបាលរាជធានី ខេត្តត្រូវបន្តទទួលចំណែកប្រាក់រង្វាន់តាមការកំណត់ក្នុងប្រកាសរួម ឬប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមី។

**មាត្រា៨.-**

ការបែងចែកចំណូលដែលបានពីកម្រៃនៃការផ្តល់សេវាសាធារណៈផ្សេងៗទៀត តាមរយៈការប្រគល់ ឬការធ្វើប្រតិភូកម្មមុខងារពីក្រសួង ស្ថាប័ននានាត្រូវអនុវត្តតាមការបែងចែកដូចខាងក្រោម៖

១.ចំណែកចំណូលគុណប្រយោជន៍ថវិការបស់រដ្ឋបាលរាជធានី ខេត្ត គឺជាចំណែកថវិកាដែលនៅសល់ពីការបែងចែកប្រាក់រង្វាន់។

២. ចំណែកប្រាក់រង្វាន់៖

- ផ្តល់ជូនក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ រដ្ឋបាលឃុំ សង្កាត់ ទៅតាមអត្រាជាភាគរយធៀបនឹងចំណូលប្រមូលបានដែលកំណត់ដោយប្រកាសរួម ឬប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ
- ផ្តល់ជូនរដ្ឋបាលរាជធានី ខេត្តសាមី ចំនួន៣(បី)ភាគរយនៃចំណូលប្រមូលបាន
- ផ្តល់ជូនអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ចំនួន១(មួយ)ភាគរយនៃចំណូលប្រមូលបាន។

អត្រានៃការបែងចែកចំណែកប្រាក់រង្វាន់ខាងលើនេះ អាចត្រូវបានកែសម្រួលដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមីនីមួយៗ។

**មាត្រា៩.-**

ការគ្រប់គ្រង និងការបែងចែកប្រាក់រង្វាន់សម្រាប់លើកកម្ពស់សមត្ថភាពស្ថាប័នដើម្បីពង្រឹងយន្តការប្រមូលចំណូល និងឧបត្ថម្ភលើកទឹកចិត្តបុគ្គលិកនៃរដ្ឋបាលរាជធានី ខេត្ត មន្ទីរ អង្គភាព ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធដទៃទៀតត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា១០.-**

រដ្ឋបាលរាជធានី ខេត្តត្រូវបង់ចំណូលថវិកាដែលបានពីកម្រៃនៃការផ្តល់សេវានៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្តទៅតាមលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីជាធរមាន។

## ជំពូកទី៣
## ការគ្រប់គ្រងចំណាយ

**មាត្រា១១.-**

ដោយផ្អែកលើទំហំចំណូលដែលបានគ្រោងពីកម្រៃសេវារដ្ឋបាល និងសេវាសាធារណៈរបស់អង្គភាពច្រកចេញចូលតែមួយ រដ្ឋបាលរាជធានី ខេត្តត្រូវគ្រោងឥណទានចំណាយប្រាក់រង្វាន់ ដូចកំណត់ក្នុងមាត្រា៨នៃអនុក្រឹត្យនេះ និងចំណាយសម្រាប់អភិវឌ្ឍមូលដ្ឋាន នៅក្នុងគម្រោងចំណាយថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្តនីមួយៗទៅតាមចំណាត់ថ្នាក់នៃមាតិកាថវិកា។

**មាត្រា១២.-**

ចំណាយសម្រាប់ប្រតិបត្តិការរដ្ឋបាលរបស់អង្គភាពច្រកចេញចូលតែមួយ ត្រូវគ្រោងនៅក្នុងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្តនីមួយៗទៅតាមចំណាត់ថ្នាក់នៃមាតិកាថវិកា។

**មាត្រា១៣.-**

រដ្ឋបាលរាជធានី ខេត្តត្រូវអនុញ្ញាតឱ្យកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់លើកទឹកចិត្តតាមទំហំ និងអត្រាដូចបានកំណត់ក្នុងមាត្រា៧ និងមាត្រា៨នៃអនុក្រឹត្យនេះ ដែលចំណែកនេះត្រូវបានចាត់ទុកថារដ្ឋបាលរាជធានី ខេត្តបានដកប្រាក់មុននូវចំណែកប្រាក់រង្វាន់សម្រាប់លើកកម្ពស់សមត្ថភាពស្ថាប័ន ដើម្បីពង្រឹងយន្តការប្រមូលចំណូល និងឧបត្ថម្ភលើកទឹកចិត្តបុគ្គលិកនៃរដ្ឋបាលរាជធានី ខេត្ត មន្ទីរ អង្គភាព ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធដទៃទៀត។

**មាត្រា ១៤.-**

រដ្ឋបាលរាជធានី ខេត្តត្រូវបើកផ្តល់ប្រាក់រង្វាន់ដែលត្រូវផ្តល់ជូនមន្ទីរ អង្គភាព ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធដទៃទៀតទៅតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

រដ្ឋបាលរាជធានី ខេត្តត្រូវធ្វើការទូទាត់ប្រាក់រង្វាន់លើកទឹកចិត្តសរុបដែលបានកាត់ទុកជាមុនតាមគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន។

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**មាត្រា១៥.-**

នៅក្នុងឆមាសទី១ ឆ្នាំ២០២០ មន្ទីរជំនាញរាជធានី ខេត្តទាំងអស់ត្រូវជួយរៀបចំសលាកប័ត្របង់ចំណូល ឬដីកាសម្រង់សលាកប័ត្របង់ចំណូលថវិកាជូនសមុខឱ្យរដ្ឋបាលរាជធានី ខេត្ត ដើម្បីផ្ទេរចំណូលមិនមែនសារពើពន្ធរបស់មន្ទីរជំនាញរាជធានី ខេត្ត ១០០% ដែលប្រមូលបាននៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត ឱ្យចូលថវិការដ្ឋបាលរាជធានី ខេត្ត ។

**មាត្រា១៦.-**

ក្រសួង ស្ថាប័នដែលកំពុងអនុវត្តការប្រមូលចំណូលពីការផ្តល់សេវាដែលបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការផ្ទេរប្រាក់តាមប្រព័ន្ធធនាគារ ឬតាមរយៈភ្នាក់ងារផ្តល់សេវាផ្ទេរប្រាក់

ត្រូវផ្ទេរប្រព័ន្ធគ្រប់គ្រង និងការប្រមូលចំណូលពីប្រភេទសេវាទាំងនោះទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថកិច្ចឱ្យបានក្នុងឆមាសទី១ ឆ្នាំ២០២០។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា១៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងពាក់ព័ន្ធ ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សា និង គណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមមេត្តាចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- លេខាធិការដ្ឋាន គ.ជ.អ.ប
- ដូចមាត្រា១៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ